- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ...៧៤៨...អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់ គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

## សម្រេច

### ជំពូកទី១
### បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ ដែលសរសេរជាអក្សរកាត់ថា "**គ.អ.ល.**" ដើម្បីអនុវត្ត "គោលនយោបាយស្តីពីការលើកទឹកចិត្ត និងការបង្កើតកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ" ពាក់ព័ន្ធនឹងការលើកទឹកចិត្តផ្នែកសារពើពន្ធ ផ្នែកវិនិយោគសាធារណៈ និងនិយ័តកម្ម ប្រកបដោយប្រសិទ្ធភាព សមភាព និងភាពប្រកួតប្រជែង។

## ជំពូកទី២

## សមាសភាពនិងភារកិច្ច

**មាត្រា២.-**

**គ.អ.ល.** មានសមាសភាពដូចខាងក្រោម÷

| | |
|---|---|
| ១- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | អនុប្រធាន |
| ៣- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| ៤- ប្រធានក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៥- ប្រធានក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |

សមាសភាពជាក់ស្តែងនៃ **គ.អ.ល.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**មាត្រា៣.-**

**គ.អ.ល.** មានភារកិច្ច ដូចតទៅ÷

- ពិនិត្យ និងពិភាក្សាលើសំណើគម្រោងអភិវឌ្ឍន៍លំនៅឋានសមរម្យ ដើម្បីស្នើសុំការសម្រេចរបស់រាជរដ្ឋាភិបាល
- អនុម័តលើគោលការណ៍ណែនាំ និងនីតិវិធីនៃការរៀបចំ ពិនិត្យ អនុវត្ត និងគ្រប់គ្រងគម្រោងអភិវឌ្ឍន៍លំនៅឋានសមរម្យ
- កំណត់របៀបវារៈក្នុងដំណើរការតាមដាន និងត្រួតពិនិត្យ តាមដំណាក់កាលនីមួយៗនៃការអនុវត្តគម្រោង
- រៀបចំយុទ្ធសាស្ត្រទាក់ទាញដៃគូវិស័យឯកជនចូលរួមក្នុងកម្មវិធីអភិវឌ្ឍលំនៅឋានតម្លៃសមរម្យ និង
- បំពេញតួនាទីជាអ្នកនាំពាក្យ ឬ ទំនាក់ទំនងសាធារណៈក្នុងការផ្សព្វផ្សាយ និងឆ្លើយតបចំពោះវិនិយោគិនសក្តានុពលក្នុងនាមរាជរដ្ឋាភិបាល។

## ជំពូកទី៣

## ដំណើរការការងារ

**មាត្រា៤.-**

សមាសភាព **គ.អ.ល.** ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន។ ក្នុងករណីប្រធានអវត្តមាន អនុប្រធានអាចកោះអញ្ជើញ និងដឹកនាំការប្រជុំ **គ.អ.ល.** តាមការប្រគល់សិទ្ធិរបស់ប្រធាន។

**គ.អ.ល.** មានរបបប្រជុំសាមញ្ញ ប្រចាំត្រីមាស ឆមាស និងប្រចាំឆ្នាំ ព្រមទាំងអាចប្រជុំជាវិសាមញ្ញ តាមការចាំបាច់។

**គ.អ.ល.** មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការងាររបស់ខ្លួន។

**មាត្រា៥.-**

**គ.អ.ល.** អាចស្នើសុំកិច្ចសម្របសម្រួល និងសហប្រតិបត្តិការពីគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីពិនិត្យ និងផ្តល់យោបល់លើការពិនិត្យ និងវាយតម្លៃគម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ។

**មាត្រា៦.-**

**គ.អ.ល.** មានក្រុមការងារបច្ចេកទេសពីរជាសេនាធិការ រួមមាន ក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក្នុងការបំពេញមុខងារ និងភារកិច្ចរបស់ខ្លួន។

ក្រុមការងារបច្ចេកទេសក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ក្រុមការងារបច្ចេកទេសក្រសួងរៀបចំដែនដីនគរូបនីយកម្មនិងសំណង់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

**មាត្រា៧.-**

**គ.អ.ល.** មានលេខាធិការដ្ឋានមួយ ដែលមានភារកិច្ចជួយសម្របសម្រួល និងផ្តល់ការគាំទ្រដល់ក្រុមការងារបច្ចេកទេសទាំងពីរ ក្នុងការបំពេញតួនាទីជាសេនាធិការ ជូនគណៈកម្មាធិការអន្តរក្រសួងសម្រាប់គម្រោងអភិវឌ្ឍន៍លំនៅឋានតម្លៃសមរម្យ។

កិច្ចដំណើរការ និងសមាសភាពនៃលេខាធិការដ្ឋាននេះ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

## ជំពូកទី៤

## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ឱ្យមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃ សុក្រ ១៤ កើត ខែ មិគសិរ ឆ្នាំរកា ព.ស. ២៥៦១

ត្រូវនឹងថ្ងៃទី ០១ ខែ ធ្នូ គ.ស. ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល÷**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**អូន ព័ន្ធមុនីរ័ត្ន**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ : ២៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

<u>**សម្រេច**</u>

**មាត្រា១.**_

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ១៧ ៩៣២ ០០០ ០០០ រៀល (ដប់ប្រាំពីរប៊ីលានប្រាំបួនរយសាមសិបពីរលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦០ (ការទិញ) ជូនក្រសួងមហាផ្ទៃ (សន្តិសុខសាធារណៈ) សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២.**_

ការបែងចែកឥណទានថវិកាចំណាយផ្ទៃក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ទិញឧបករណ៍ការពារបាតុកម្មចំនួន ០៩មុខ។

**មាត្រា៣.**_

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃ សុក្រ ១២ កើត ខែ បុស្ស ឆ្នាំរកា ព.ស. ២៥៦១
ត្រូវនឹងថ្ងៃទី ២៩ ខែ ធ្នូ គ.ស. ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៧៥០ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការផ្ទេរឥណទានថវិកា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២១៦/០១៩ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៦៤ អនក្រ.បក ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការបែងចែកឥណទានចំណាយថវិកាថ្នាក់ជាតិតាមជំពូកនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**<u>សម្រេច</u>**

**មាត្រា១.-**

ត្រូវបានអនុញ្ញាតឱ្យផ្ទេរឥណទានថវិកាចំនួន ៤០០ ០០០ ០០០ រៀល (បួនរយលានរៀលគត់) ពីជំពូក ៦៩ (ចំណាយមិនបានគ្រោងទុក) នៃខ្ទង់ចំណាយមិនទាន់បែងចែកមកជំពូក ៦១ (សេវាកម្ម) ជូនក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច សម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

**មាត្រា២.-**

ការបែងចែកឥណទានថវិកាចំណាយផ្ទេរក្នុងជំពូកនេះតាមគណនីនិងអនុគណនី ត្រូវធ្វើឡើងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្តល់ជូនមន្ទីរទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ចខេត្តកំពង់ឆ្នាំង និងខេត្តកំពង់ធំ សម្រាប់ចំណាយចាក់ដីបំពេញទំនាបក្នុងបរិវេណជុំវិញអគារ និងតម្រៀបដីសម្រាប់ផ្លូវចេញ ចូលអគារ។

**មាត្រា៣.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច/ឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ: ០១ អនក្រ.បក**

# អនុក្រឹត្យ
## ស្ដីពី

## ការកាត់ដីទំហំ ២ ៩៦៧ ហិកតា នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចេញពីដីអតីតសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាពីម៉ិច និងចេញពីដីគម្របព្រៃឈើ ឆ្នាំ ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ សម្រាប់ធ្វើប្រទានកម្មជាកម្មសិទ្ធិជូនបញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងជូនប្រជាពលរដ្ឋចំនួន ៩៤ គ្រួសារ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី ០៤ ខែមេសា ឆ្នាំ ២០១៦ ស្ដីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៩/០៩ ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ១៩៩៩ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យ ប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឲ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីព្រៃឈើ

- បានឃើញព្រះរាជក្រឹត្យលេខនស/រកត/០៨០៦/៣៣៩ ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៦ ស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋនិងរបស់នីតិបុគ្គលសាធារណៈ
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការបង្កើត និងកំណត់តំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ៦២ អនក្រ.បក ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៩ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- បានឃើញអនុក្រឹត្យលេខ ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ ៥៥ អនក្រ.បក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានឃើញអនុក្រឹត្យលេខ១៤៦ អនក្រ.បកចុះថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញសារាចរលេខ ០២ សរ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ស្តីពីការកាន់កាប់ដីរដ្ឋដោយខុសច្បាប់
- លិខិតលេខ ១៥១២ សជណ ចុះថ្ងៃទី ០៥ ខែធ្នូ ឆ្នាំ ២០១១ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ៤៩៣/១៧ ល.ស ចុះថ្ងៃទី ១២ ខែ តុលា ឆ្នាំ ២០១៧ របស់រដ្ឋបាលខេត្តកំពង់ឆ្នាំង
- លិខិតលេខ ២៤៣០ ដនស/អសក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០១៧ របស់ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់
- លិខិតលេខ ៩៦៧៥ កសក ចុះថ្ងៃទី ០៨ ខែវិច្ឆិកា ឆ្នាំ ២០១៧ របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## សម្រេច

**មាត្រា ១** : ត្រូវបានកាត់ផ្ទៃដីទំហំ **២ ៩៧៥ ហិកតា** ចេញពីអតីតសម្បទានសេដ្ឋកិច្ចក្រុមហ៊ុន ភាពីម៉ិច និងចេញពីដីគម្របព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគជាដីឯកជនរបស់រដ្ឋ ក្នុងនោះទំហំ **២ ៧៣៧ ហិកតា** សម្រាប់បង្កើតទីលានបាញ់គ្រាប់ពិតកាំភ្លើងធំគ្រប់ប្រភេទ ទីតាំងឈរជើងវរសេនាតូចកាំភ្លើងធំលេខ ៨២ ៨៣ ៨៥ និងតំបន់អភិវឌ្ឍន៍របស់បញ្ជាការដ្ឋានកាំភ្លើងធំ អគ្គបញ្ជាការដ្ឋាន នៃកងយោធពលខេមរភូមិន្ទ និង**ទំហំ ២២០ ហិកតា** ប្រទានកម្មជាកម្មសិទ្ធិជូនប្រជាពលរដ្ឋដែលបានកាន់កាប់ដាំដុះដាក់ស្តែង និងរក្សាទុកជាដីសាធារណៈរបស់រដ្ឋ នៅ**ភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង** តាមប្រព័ន្ធកូអរដោណេ Project UTM Zone 48N Datum WGS 1984 និងមាននិយាមកាដូចកំណត់ក្នុងផែនទីឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ២** : ត្រូវបានប្រគល់អាណត្តិកាន់កាប់ និងបែងចែកដីឯកជនរបស់រដ្ឋដូចមានចែងក្នុង**មាត្រា១** ជូនគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ដើម្បីធ្វើការគ្រប់គ្រង និងប្រទានកម្មជាកម្មសិទ្ធិឯកជនជូនបញ្ជាការ

ដ្ឋាន អគ្គបញ្ជាការដ្ឋាននៃកងយោធពលខេមរភូមិន្ទ និងជូនប្រជាពលរដ្ឋ ចំនួន ៩៤ គ្រួសារ នៅ**ភូមិដំណាក់អំពិល ឃុំក្រាំងស្គារ ស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ។**

**មាត្រា ៣** : ក្នុងពេលដំណើរការវាស់វែង និងបែងចែកដាក់ស្តែងគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋខេត្តកំពង់ឆ្នាំង ត្រូវកាត់ចេញនូវចំណែកដីមួយចំនួនសមស្រប ដើម្បីរក្សាទុកសម្រាប់បម្រើផលប្រយោជន៍សាធារណៈជាអាទិ៍ ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសង្គម និងអនុវត្តការចុះបញ្ជីដី រួចលើកសំណើសុំផ្តល់សិទ្ធិលើក្បាលដី តាមគោលការណ៍ និងនីតិវិធីជាធរមាន ។

**មាត្រា ៤** : បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៥** : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងអភិបាលនៃគណៈអភិបាលខេត្តកំពង់ឆ្នាំង ត្រូវអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ថ្ងៃ ៧ ១ ៤ រោច ខែបុស្ស ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ០៣ ខែមករា ឆ្នាំ ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ៖**

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការ រាជរដ្ឋាភិបាល*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា*
- *អគ្គលេខាធិការដ្ឋានអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ៥*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

**ឧបសម្ព័ន្ធអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ០៣ ខែ មករា ឆ្នាំ២០១៨ ស្តីពីការកាត់ផ្ទៃដីទំហំ ២៩៥៧ ហិកតា នៅស្រុកទឹកផុស ខេត្តកំពង់ឆ្នាំង ចេញពីតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុនតាពី មុិចនិងដីតំបន់ព្រៃឈើឆ្នាំ២០០២ និងធ្វើអនុបយោគ ជាដីឯកជនរបស់រដ្ឋជូនបញ្ជាការដ្ឋានការពារ ទំហំ ២៧៣៧ ហិកតា និងធ្វើប្រទានកម្មជូនប្រជាពលរដ្ឋទំហំ ២២០ ហិកតា**

| Id | X | Y |
|---|---|---|
| 1 | 427205 | 1348983 |
| 2 | 430137 | 1347382 |
| 3 | 425299 | 1342086 |
| 4 | 424637 | 1342070 |
| 5 | 424374 | 1341769 |
| 6 | 422998 | 1341126 |
| 7 | 422185 | 1341090 |
| 8 | 422080 | 1341467 |
| 9 | 421367 | 1341950 |
| 10 | 420971 | 1342416 |



**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៤០៣ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# ការតម្លើងឋានន្តរស័ក្តិ និងថ្នាក់មន្ត្រីរាជការ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ ២០១៣ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី ៣០ ខែ តុលា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាស ឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៦៣ ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៦០២/១៥១ ចុះថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ ២០០២ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់
- បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/០៣០០/១១៦ ចុះថ្ងៃទី ០៣ ខែ មីនា ឆ្នាំ ២០០០ ស្តីពីលក្ខន្តិកៈ ដោយឡែក នៃក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១០១៤/១១៧៥ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ២០១៤ ស្តីពី គោលការណ៍រួម នៃការរៀបចំមុខងារសាធារណៈរបស់រដ្ឋ
- បានឃើញអនុក្រឹត្យលេខ ៦៧ អនក្រ.បក ចុះថ្ងៃទី ២២ ខែ តុលា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ

## សម្រេច

**មាត្រា ១.-** តម្លើងថ្នាក់ប្រចាំឆ្នាំ ដល់មន្ត្រីរាជការចំនួន ១៧៥ រូប នៃក្របខ័ណ្ឌមន្ត្រីសុខាភិបាលជាន់ខ្ពស់ ក្របខ័ណ្ឌមន្ត្រីបច្ចេកទេសជាន់ខ្ពស់ និងក្របខ័ណ្ឌមន្ត្រីគ្រប់គ្រងរដ្ឋបាល នៅក្រសួងសុខាភិបាល ចាប់ពីថ្ងៃទី ១៣ ខែមេសា ឆ្នាំ ២០១៧ ដូចមានរាយនាមខាងក្រោម ៖

| | |
|---|---|
| ១- លោក ម៉ុង សុមន: | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២- លោក យូ ពិសី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៣- លោក អឿន បូរារ័ត្នន៍ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៤- លោក ហ៊ុយ រ៉េកុល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៥- លោក អ៊ីវ ស៊ីអួន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៦- លោក ឈុន សុជា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៧- លោកស្រី គីម វីរ័ត្តី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៨- លោក អ៊ុំ សោភារិទ្ធិ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ៩- លោក ផុង ម៉េងឡុង | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១០- លោក ប៉ូលី សំណាង | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១១- លោក គង់ ពិសិដ្ឋ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១២- លោក វ៉ា សាវ៉ន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៣- លោក លី សំបូណា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |

| | |
|---|---|
| ១៤- លោក កែវ សុវណ្ណ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៥- លោក ស្រី វណ្ណថន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៦- លោក ប៉ូ វឌ្ឍា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៧- លោក ឃុន ឃាង | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៨- លោក ហេង ហួរ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៩- លោក កៅ លុយប៉ូ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២០- លោក អ៊ុង នរិទ្ធ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២១- លោក ម៉ក់ គីមលី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២២- លោក ហាស់ ផលមុនី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៣- លោក អ៊ឹម ប៊ុនធឿន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៤- លោក អ៊ិត ប៊ុណ្ណដារ៉ា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៥- លោក ឱក វិជិត | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ២៦- លោក អ៊ិន ទិត្យារស្មី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ២៧- លោក ឈឹម វិជ្ជា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ២៨- លោក ជូ មុនីដារិទ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ២៩- លោក ស៊ិន សុវត្ថា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |

៣០- លោក ទង់ ណាង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣១- លោក សុខ លី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣២- លោក សៅ សុភាពរ៉ា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៣- លោកស្រី ស៊ឹម សុខមុយ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៤- លោក សម ផេង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៥- លោក កែវ អៀងលី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៦- លោក ហ្វួត សុគុណ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៧- លោក សុខ សំអាត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៨- លោក ពាស់ មូស្លឹម ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៣៩- លោក ស៊ុង វិនត: ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤០- លោក ជ្រឿ សុខណាង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤១- លោក ឯក សុវណ្ណមុនី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤២- លោកស្រី គី ស៊ីវ៉ាន់ថា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤៣- លោក កែវ លីអ៊ីង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤៤- លោក ថូ សុចន្ថា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

៤៥- លោក កាអឿន ចិត្រា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

| | |
|---|---|
| ៤៦- លោក ប៉ែន ម៉ារនី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៤៧- លោក លី វុទ្ធនី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៤៨- លោកស្រី គង់ ស៊ននី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៤៩- លោក សោម ជុំដាកា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥០- លោក ឡាវ ចន្ថា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥១- លោក ស៊ុយ សុភាព | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥២- លោកស្រី យុត សុធីណា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៣- លោក ទៅ ម៉ឹង | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៤- លោកស្រី ឈុន វ៉ារុជ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៥- លោក ភួង ចាន់ថន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៦- លោក សុត វុទ្ធី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៧- លោក គង់ ណារិទ្ធ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២ |
| ៥៨- លោក សេង សុភាព | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៥៩- លោកស្រី ឡាយ វ៉ារី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦០- លោក សុខ គន្ធី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦១- លោក ប៊ិចចំណាន វិសាល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |

| | |
|---|---|
| ៦២- លោក កែវ ឌីណាម៉ូរ៉ា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៣- លោក គៀន សម្ភារ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៤- លោក យ៉ែម សុផល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៥- លោក ឡាយ សុជាតិ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៦- លោក គង់ រិទ្ធី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៧- លោក មុំ សុបញ្ញា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៨- លោក ចាន់ សែ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៦៩- លោក អួន ពៅ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧០- លោក ណុប សុជេត | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧១- លោក ស៊ា សុគន្ធ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧២- លោក សួរ សារ៉ាន់ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧៣- លោក សៅ សុគន្ធវឌ្ឍនា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧៤- លោកស្រី អ៊ុន យូ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧៥- លោក ជួង សុខណារិន | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧៦- លោក លី វីរៈ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ៧៧- ឯកឧត្តម សាន់ សាប់អ៊ី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |

៧៨- លោក ប៊ុនថាន់ យុត្តិរុង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៧៩- លោក សន សំអឿន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨០- លោក អ៊ុក សារ៉ីម ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨១- លោក ប៊ូ សុភាព ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨២- លោក ងូ គីមផន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៣- លោក ម៉ែន សារិន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៤- លោក លេខ មុយហួ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៥- លោក អ៊ុង ម៉ាលីនាត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៦- លោក ព្រាប ឡី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៧- លោក នី ថារ័ត្ន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៨- លោក កែវ ណារិទ្ធ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៨៩- លោក តុង ហុង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩០- លោក ឈាង ឃោ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩១- លោក ឆាយ រស្មី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩២- លោក ចាន់ វីរៈ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៣- លោក សេង សាគរី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៤- លោក ចាន់ វិចិត្រ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៥- លោកស្រី សុផុន សុគន្ធារី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៦- លោក លី សម្បត្តិ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៧- លោកស្រី អ៊ិក សំបុន្នី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៨- លោក នុត យុទ្ធា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

៩៩- លោក ឡាយ សម្បត្តិ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០០- លោកស្រី ជន ស៊ីនួន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០១- លោកស្រី ងី ពេជ្រប្រសិទ្ធ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០២- លោក ស៊ួយ ប៊ុនណារេត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៣- លោក ហួ វីរៈ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៤- លោក ហេង មិត្តកា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៥- លោក ឡាច វ៉ាន់ឌឿន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៦- លោកស្រី គ្រៀល ដាវ៉ា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៧- លោកស្រី ជា ស៊ីផន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៨- លោក អ៊ិក ភីរម្យ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១០៩- លោកស្រី អេង ឈីវរ៉ុង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១០- លោក ហៃ ឡៃសុន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១១- លោក នួន សង្វាត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១២- លោក ទូច ផល្លា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៣- លោកស្រី លី ប៉ូលីន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៤- លោក ម៉េង ហួត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៥- លោក យក់ សុវណ្ណ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៦- លោក សៀក រតនៈ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៧- លោក ទុយ ពេជ្រ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៨- លោក នូ សុខបូណា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១១៩- លោក ប៊ិច សុធី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១២០- លោក ជី សុជាតិ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១២១- លោកស្រី ឈូ វណ្ណា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១២២- លោកស្រី ហ៊ីង សាវី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣

១២៣- លោក ម៉ម ចាន់សាអូន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១២៤- លោក ច័ន្ទ ជំនាញ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១២៥- លោក ឡាយ ឡង់ឌី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

| | |
|---|---|
| ១២៦- លោកស្រី យឹម កញ្ញាណា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១២៧- លោក កែវ វណ្ណថា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១២៨- លោកស្រី ច័ន្ទ ពិសី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១២៩- លោក សែម អ៊ុច | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣០- លោក គង់ សុខឌីណា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣១- លោក ប៊ុន វឌ្ឍនៈ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣២- លោក អ៊ឹង ឡាយ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៣- លោកស្រី ម៉ៅ សុខនី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៤- លោកស្រី សំ សុភាព | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៥- លោកស្រី អ៊ុច មោនីភាព | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៦- លោក នី បូផល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៧- លោក ទៀង វិរៈរដ្ឋា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៨- លោកស្រី ហេង សុខាវ៉ានី | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៣៩- លោក ហាក់ មេសា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៤០- លោក ស្បួស កុល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៤១- លោក ខៀវ វិចិត្រ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១ |
| | មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |

១៤២- លោក រិន រ៉ាវុឌ្ឍន៍ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៣- លោក វេង ឡុង ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៤- លោកស្រី សុង សោភា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៥- លោក សោ ដា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៦- លោកស្រាង គន្ធា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៧- លោក ទឹម ឃុន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៨- លោក ហូ សុខហួន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៤៩- លោក ឱន ចំនិត ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥០- លោក ហាម វឌ្ឍា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥១- លោក កែវ សារ៉ាវុធ ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥២- លោកស្រី ប៉ែន អ៊ុងវីរ៉ា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥៣- លោក ស្វាយ សុម៉ាណា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥៤- លោកស្រី គា ចាន់ថី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥៥- លោក ខឹម មុនីកុសល ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥៦- លោក សាខុន យុទ្ធី ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

១៥៧- លោកស្រី យីវ សុកអឿន ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១
មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤

| | |
|---|---|
| ១៥៨- លោក សំរិត មូល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៥៩- លោកស្រី លឹម សិលា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦០- លោក បាន វត្ថា | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦១- លោក គៀល សុផល | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦២- លោក គុណ ណារុធ | ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៣- លោកស្រី គង់ ណារីន | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៦៤- លោកស្រី កែវ សុទ្ធី | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ១ |
| ១៦៥- លោកស្រី ចៅ ម៉ាលីន | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ១៦៦- លោក ស្រ៊ុញ វីរៈជាតិ | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ១៦៧- លោក ឃិន កាតេរ៉ូ | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ |
| ១៦៨- លោក សាវ៉ាយ ច័ន្ទវិទ្ធីយ៉ា | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៦៩- លោក អោក វិបុល | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧០- លោក វ៉ើ ដាយ៉ា | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧១- លោកស្រី សារ លក្ខណ៍កញ្ញា | ពីមន្ត្រីបច្ចេកទេសជាន់ខ្ពស់ ថ្នាក់លេខ ១<br>មកមន្ត្រីបច្ចេកទេសជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៤ |
| ១៧២- លោកស្រី ញ៉ែម អេងហួន | ពីវរមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ១ |
| ១៧៣- លោក ឡាយ សូនី | ពីវរមន្ត្រី ថ្នាក់លេខ ២ មកវរមន្ត្រី ថ្នាក់លេខ ១ |

១៧៤- លោក យក់ សម្ផស្ស ពីអនុមន្ត្រី ថ្នាក់លេខ ១ មកវរមន្ត្រី ថ្នាក់លេខ ៤

**-ផ្តល់ឋានន្តរស័ក្តិកិត្តិយសមុនពេលចូលនិវត្តន៍**

១៧៥- លោកស្រី អ៊ូ វណ្ណដា ពីមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ៣ មកមន្ត្រីសុខាភិបាលជាន់ខ្ពស់ដើមខ្សែ ថ្នាក់លេខ ២

**មាត្រា ២ .-** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួនដូចមានចែងក្នុងមាត្រា ១ ខាងលើ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅ រាជធានីភ្នំពេញ ថ្ងៃ ពុធ ១០រោច ខែមិគសិរ ឆ្នាំរកា ព.ស ២៥៦១

ត្រូវនឹង ថ្ងៃទី ១៣ ខែ ធ្នូ គ.ស ២០១៧

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

***កន្លែងទទួល***

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *អគ្គលេខាធិការរាជរដ្ឋាភិបាល*
- *ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី*
- *ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *រាជកិច្ច*
- *ឯកសារ-កាលប្បវត្តិ*

រក្សាសិទ្ធ និងបោះពុម្ពដោយ
អគ្គនាយកដ្ឋានរាជកិច្ច និងសេវាកុំព្យូទ័រ
នៃ ទីស្ដីការគណៈរដ្ឋមន្ត្រី